UNITED NATIONS
CAMBODIA

# ការគាំទ្ររបស់អង្គការសហប្រជាជាតិ ដល់យុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ទូទាំងប្រទេសនៅកម្ពុជា

## ឯកសារព័ត៌មានទី ១១

## ថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០២១

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ទូទាំងប្រទេស កាលពីថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២១ ជាមួយនឹងគោលដៅចាក់វ៉ាក់សាំងដល់ពលរដ្ឋពេញវ័យចំនួន ១០ លាននាក់ឱ្យហើយ ត្រឹមចុងឆ្នាំ ២០២១។ ក្រុមអាទិភាពដែលត្រូវទទួលវ៉ាក់សាំង រួមមាន បុគ្គលិកសុខាភិបាលជួរមុខ មនុស្សចាស់ អ្នកដែលមានជំងឺប្រចាំកាយ និងប្រជាជនពេញវ័យទូទៅ។ គិតត្រឹមថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០២១ មានពលរដ្ឋសរុបចំនួន ៦,៦ លាននាក់[1] បានទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ដូសទី ១ និង ៤,៤ លាននាក់[2] បានទទួលវ៉ាក់សាំងដូសទី ២។ ក្នុងចំណោមប្រជាជនគោលដៅ ស្ត្រី ៥០% បានទទួលដូសទី ១ ខណៈពេលដែល ៤៩% បានទទួលដូសទី ២។ ការចាក់វ៉ាក់សាំងជូនមនុស្សចាស់អាយុចាប់ពី ៦០ ឆ្នាំឡើងទៅ នៅតែបន្តចាត់ទុកថាជាសកម្មភាពអាទិភាព ដែលត្រូវពន្លឿនបន្ថែម ហើយគិតត្រឹមពាក់កណ្តាលខែ មិថុនា ឆ្នាំ ២០២១ បុគ្គលិកសុខាភិបាល ៩៣% បានទទួលវ៉ាក់សាំងដូសទី ២។ បើទោះជាការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ នៅទូទាំងសកលលោកជួបនឹងឧបសគ្គក្តី រាជរដ្ឋាភិបាលតាមរយៈកិច្ចលទ្ធកម្មទ្វេភាគី យន្តការកូវ៉ាក់ និងការផ្តល់វ៉ាក់សាំងជាអំណោយ អាចធានាបាននូវចំនួនវ៉ាក់សាំងកូវីដ-១៩ ជាបន្តបន្ទាប់ ដើម្បីសម្រេចតាម គោលដៅរបស់ខ្លួន។ គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាបានទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ចំនួន ១៧.៣៥៦.០០០ ដូស និងមានវ៉ាក់សាំងបន្ថែមទៀតនឹងមកដល់នៅខែបន្តបន្ទាប់។

កម្ពុជា គឺជាប្រទេសមួយ ក្នុងចំណោមប្រទេស នៅតំបន់ប៉ាស៊ីហ្វិកទាំងភាគខាងលិចរបស់អង្គការសុខភាពពិភពលោក ដែលបានចាក់វ៉ាក់សាំងដល់ពលរដ្ឋជាមនុស្សពេញវ័យរបស់ខ្លួន ក្នុងភាគរយខ្ពស់បំផុត ហើយស្ថិតនៅក្នុងចំណោមប្រទេសចំនួន ១៧ ក្នុងពិភពលោកដែលបានចាក់វ៉ាក់សាំងឱ្យគ្រូបង្រៀនដំបូងគេ។ ផ្អែកតាមទិន្នន័យដែលមាន ភាពស្ទាក់ស្ទើរក្នុងការចាក់វ៉ាក់សាំងនៅកម្ពុជាមានកម្រិតទាប បើធៀបនឹងប្រទេសដទៃទៀតនៅក្នុងពិភពលោក។ ចាប់តាំងពីពេលការផ្ទុះជំងឺកូវីដ-១៩នៅក្នុងសហគមន៍ជាទ្រង់ទ្រាយធំកាលពីខែ កុម្ភៈ ឆ្នាំ ២០២១ មក យុទ្ធនាការចាក់វ៉ាក់សាំងត្រូវបានអនុវត្តជាបន្តបន្ទាប់ ដោយមានការផ្តល់អាទិភាពដល់

[1] ៦.៦៤៨.៤៧៣ នាក់ ស្មើនឹង ៦៦% នៃចំនួនប្រជាជនគោលដៅជាមនុស្សពេញវ័យ និង ៣៩% នៃចំនួនប្រជាជនសរុបនៅក្នុងប្រទេស។

[2] ៤.៤៣១.២៥២ នាក់ ស្មើនឹង ៤៤% នៃចំនួនប្រជាជនគោលដៅជាមនុស្សពេញវ័យ និង ២៩% នៃចំនួនប្រជាជនសរុបនៅក្នុងប្រទេស។

តំបន់ និងក្រុងដែលប្រឈមមុខខ្ពស់ទៅនឹងការឆ្លងជំងឺនេះ ហើយក្នុងពេលជាមួយគ្នា មានការពង្រីកយុទ្ធនាការចាក់វ៉ាក់សាំងជាបន្តបន្ទាប់ទៅកាន់តំបន់ដទៃទៀតនៅក្នុងប្រទេស។ រាជរដ្ឋាភិបាលបានបង្កើតនូវគណៈកម្មាធិការកម្រិតខ្ពស់ច្រើន ដូចជា គណៈកម្មាធិការចំពោះកិច្ចសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលមានអនុគណៈកម្មាធិការចំនួន ៥ និងគណៈកម្មាធិការថ្នាក់ខេត្ត ដើម្បីធានាការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងឱ្យមានប្រសិទ្ធភាពនៅទូទាំងប្រទេស ក៏ដូចជា ដើម្បីឆ្លើយតបចំពោះការឆ្លងជំងឺកូវីដ-១៩ តាមសហគមន៍ជាទ្រង់ទ្រាយធំដែលនៅកំពុងបន្តកើតមាន រួមទាំងការគំរាមកំហែងដែលបង្កឡើងដោយវីរុសបំប្លែងថ្មីដែលតាផងដែរ។ បច្ចុប្បន្ននេះ កម្ពុជាអាចប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩មួយចំនួន ដូចជា Sinovac Sinopharm និង AstraZeneca/Covishield ដែលសុទ្ធតែបានទទួលការអនុម័តពីអង្គការសុខភាពពិភពលោក[3] និងមានផែនការបញ្ចូលវ៉ាក់សាំង Janssen (Johnson&Johnson) ទៅក្នុងក្រុមវ៉ាក់សាំងសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសផងដែរ។ ចំនួនដូសវ៉ាក់សាំងដែលត្រូវបានលើកជាអនុសាសន៍ នៅក្នុងបញ្ជីវ៉ាក់សាំងសម្រាប់ប្រើប្រាស់ក្នុងស្ថានភាពបន្ទាន់របស់អង្គការសុខភាពពិភពលោក ត្រូវបានរកឃើញថាអាចផ្តល់ការការពារបានយ៉ាងល្អបំផុតពីការកើតជំងឺធ្ងន់ធ្ងរ និងការព្យាបាលនៅក្នុងមន្ទីរពេទ្យ ដែលអាចបង្កឡើងដោយវីរុសបំប្លែងថ្មីដែលតា ក៏ដូចជាវីរុសបំប្លែងថ្មីដែលគួរឱ្យបារម្ភដទៃទៀត។

អង្គការសហប្រជាជាតិ បាននិងកំពុងជួយដល់ការអនុវត្តយុទ្ធនាការឆ្លើយតបចំពោះជំងឺកូវីដ-១៩ និងយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩របស់រាជរដ្ឋាភិបាល ដោយចាត់ទុកអន្តរាគមន៍នេះថាជាអាទិភាពខ្ពស់បំផុត។ ជារួមអង្គការសហប្រជាជាតិត្រូវផ្តោតលើការពង្រឹងប្រព័ន្ធសុខាភិបាល ជាផ្នែកមួយនៃការកសាងឡើងវិញឱ្យកាន់តែប្រសើរ ជំរុញដោយការចាក់វ៉ាក់សាំងប្រកបដោយសមធម៌ និងធានាយ៉ាងណាឱ្យអ្នកដែលប្រឈមមុខខ្ពស់ជាងគេក្នុងការឆ្លងជំងឺកូវីដ-១៩ បានទទួលវ៉ាក់សាំងមុនគេ។ ស្របតាមគោលការណ៍នេះ អង្គការសហប្រជាជាតិ បានផ្តល់ការគាំទ្របច្ចេកទេសដល់រាជរដ្ឋាភិបាល ក្នុងការរៀបចំផែនការចាក់វ៉ាក់សាំងថ្នាក់ជាតិ (NDVP) និងគោលការណ៍ណែនាំប្រតិបត្តិស្តីពីជំងឺកូវីដ-១៩ សម្រាប់ការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងផងដែរ។ ប្រទេសកម្ពុជាបានចូលរួមជាមួយនឹងយន្តការកូវ៉ាក់ ដែលជាយន្តការសកល គ្រប់គ្រងដោយ GAVI CEPI និង WHO ក្នុងគោលបំណងធានាយ៉ាងណាឱ្យវ៉ាក់សាំងកូវីដ-១៩មានតម្លៃសមរម្យ និងអាចរកបានសម្រាប់គ្រប់ប្រទេសទាំងអស់។ អង្គការសហប្រជាជាតិ បាននិងកំពុងធ្វើការងារ ដើម្បីធានាយ៉ាងណាឱ្យកម្ពុជាអាចទទួលបានវ៉ាក់សាំងកូវីដ-១៩។ តាមរយៈកម្មវិធីអន្តរវិស័យ និងភាពជាដៃគូជាយុទ្ធសាស្ត្ររបស់ខ្លួន អង្គការសហប្រជាជាតិកំពុងគាំទ្រដល់រាជរដ្ឋាភិបាល ដើម្បីធានាយ៉ាងណាឱ្យក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះអាចទទួលបានព័ត៌មានសុក្រឹត និងទាន់ពេលវេលាអំពីវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ក៏ដូចជាទទួលបាន

[3] វ៉ាក់សាំងទាំងនេះត្រូវបានបញ្ចូលទៅក្នុងបញ្ជីវ៉ាក់សាំងសម្រាប់ប្រើប្រាស់ក្នុងស្ថានភាពបន្ទាន់ (EUL) និងបានទទួលការអនុញ្ញាតសម្រាប់ប្រើប្រាស់ក្នុងស្ថានភាពបន្ទាន់ (EUA)។

សេវាវ៉ាក់សាំងដែលមានគុណភាព និងសុវត្ថិភាព។ ការផ្តល់ជំនួយជាក់លាក់របស់អង្គការសហប្រជាជាតិដល់រាជរដ្ឋាភិបាល រួមនឹងថវិកាដែលបានទទួលពីអ្នកផ្តល់ជំនួយសំខាន់ៗ រួមមាន៖

- ការផ្តល់ជំបូន្មានយុទ្ធសាស្ត្រ និងបច្ចេកទេសដល់គណៈកម្មាធិការចំពោះកិច្ច អនុគណៈកម្មាធិការ និងក្រសួងសុខាភិបាល សម្រាប់យុទ្ធនាការចាក់វ៉ាក់សាំង
- ការវាយតម្លៃលើសមត្ថភាព និងតម្រូវការ និងធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំបច្ចេកទេស និងគោលការណ៍ណែនាំប្រតិបត្តិពាក់ព័ន្ធ
- ការធ្វើលទ្ធកម្មទិញបរិក្ខារត្រជាក់ និងសម្ភារៈផ្គត់ផ្គង់ ដើម្បីធានាឱ្យមានការរក្សាទុក និងការដឹកជញ្ជូនវ៉ាក់សាំងកូវីដ-១៩ឱ្យបានគ្រប់គ្រាន់នៅគ្រប់កម្រិតទាំងអស់
- ការបណ្តុះបណ្តាលដល់ក្រុមផ្តល់វ៉ាក់សាំង អំពីរបៀបទុកដាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាព និងការគាំទ្រដល់ការតាមដាន និងគ្រប់គ្រងផលរំខានដែលកើតមានបន្ទាប់ពីចាក់វ៉ាក់សាំងរួច (AEFI)
- ការសម្របសម្រួលកម្រិតវិស័យតាមរយៈវេទិកាក្រុមដៃគូសុខាភិបាល (HPG) រាប់បញ្ចូលទាំងការសម្របសម្រួលការរួមចំណែកពីដៃគូអភិវឌ្ឍន៍ និងការកំណត់ពីហានិភ័យ និងអាទិភាពថ្មីៗ
- ការរៀបចំយុទ្ធសាស្ត្រផែនការ និងឧបករណ៍អប់រំផ្សព្វផ្សាយអំពីហានិភ័យ និងកៀរគរចលនា សហគមន៍ ដើម្បីជំរុញឱ្យមានការទទួលយកវ៉ាក់សាំងកូវីដ-១៩ រួមនឹងការបង្កើតវេទិកាស្តាប់មតិយោបល់ដែលត្រូវបានលើកឡើងជាទូទៅនៅក្នុងសង្គម
- ការរៀបចំក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ រួមគ្នាជាមួយនឹងរាជរដ្ឋាភិបាល ដូចជា ការរៀបចំឧបករណ៍សម្រាប់គ្រប់គ្រាន់ និងពិនិត្យតាមដាន ពិធីសារសម្រាប់ធ្វើការវាយតម្លៃ និងការផ្តល់ជាតុចូលបច្ចេកទេសសម្រាប់ប្រព័ន្ធអេឡិចត្រូនិកថ្មីមួយដែលប្រើប្រាស់សម្រាប់ចុះឈ្មោះ កត់ត្រា និងរាយការណ៍ពីករណីកូវីដ-១៩
- ការពិនិត្យតាមដានរួមគ្នាជាមួយនឹងរាជរដ្ឋាភិបាលលើយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការកំណត់របស់ក្រុមមនុស្សពេញវ័យការដែលងាយរងគ្រោះ និងជួយសម្រួលឱ្យពួកគេបានទទួលវ៉ាក់សាំង ដោយធ្វើការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន និងដៃគូនានា ដើម្បីធានាឱ្យការចាក់វ៉ាក់សាំងអាចធ្វើទៅបានប្រកបដោយសមធម៌ និងបរិយាប័ន្ន។ ក្រុមងាយរងគ្រោះរួមមានមនុស្សចាស់គ្រួសារក្រីក្រ ក្រុមជនជាតិភាគតិច ជនមានពិការភាព ជនអនាថា និងអ្នកដែលរស់នៅតាមមណ្ឌលថែទាំជាដើម។

កាលពីពេលថ្មីៗ រដ្ឋាភិបាលបានប្រកាសពីផែនការចាក់វ៉ាក់សាំងដល់កុមារអាយុពី ១២ ដល់ ១៧ ឆ្នាំ ចាប់ពីខែ សីហា ឆ្នាំ ២០២១។ បច្ចុប្បន្ន កំពុងមានការប្រមែប្រមូលភ័ស្តុតាង និងការរៀបចំគោលការណ៍ណែនាំស្តីពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ដល់កុមារ ជាបន្តបន្ទាប់នៅឡើយ។ ស្របតាមការណែនាំបច្ចុប្បន្ន

របស់អង្គការសុខភាពពិភពលោក អង្គការសហប្រជាជាតិផ្តល់ជាអនុសាសន៍ថា គួរបន្តផ្តល់អាទិភាពសម្រាប់ការចាក់វ៉ាក់សាំងដល់មនុស្សពេញវ័យ និងអ្នកប្រឈមមុខខ្ពស់នឹងការឆ្លងជំងឺនេះ (ដូចជា បុគ្គលិកសុខាភិបាលជួរមុខ និងភ្នាក់ងារសង្គមកិច្ច) មនុស្សចាស់ និងក្រុមដែលងាយរងគ្រោះជាងគេ ជាពិសេសខណៈពេលដែលការផ្គត់ផ្គង់វ៉ាក់សាំងសកលលោកទាំងមូល នៅមានភាពខ្វះខាតនៅឡើយ។ កុមារដែលមានបញ្ហាសុខភាពដែលមានហានិភ័យឆ្លងវីរុសកូវីដ-១៩ ធ្ងន់ធ្ងរ គួរទទួលបានវ៉ាក់សាំង ក្រោយពេលដែលមនុស្សពេញវ័យដែលមានបញ្ហាសុខភាពបានទទួលវ៉ាក់សាំងអស់។ ការចាក់វ៉ាក់សាំងដល់កុមារ និងក្មេងជំទង់ អាចជាការចាំបាច់នាពេលអនាគត ដើម្បីបន្តកាត់បន្ថយការឆ្លងវីរុសនេះ កាត់បន្ថយហានិភ័យនៃការលេចចេញនូវពពួកវីរុសបំប្លែងខ្លួនថ្មីៗ និងការពារក្រុមដែលងាយរងគ្រោះ និងដែលមិនទាន់បានទទួលការចាក់វ៉ាក់សាំង។ *សូមមើលឯកសារព័ត៌មានទី ១០ របស់អង្គការសហប្រជាជាតិស្តីពីការអប់រំ សម្រាប់ព័ត៌មានបន្ថែមអំពីការចាក់វ៉ាក់សាំងដល់កុមារ។*

ការចាក់វ៉ាក់សាំង គឺជាយុទ្ធសាស្ត្រមួយ ក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗនៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ប្រកបដោយប្រសិទ្ធភាពទន្ទឹមគ្នានឹងការចាក់វ៉ាក់សាំង គួរមានការអនុវត្តវិធានការសុខភាពសាធារណៈ និងវិធានការសង្គមដែលមានប្រសិទ្ធភាពផ្សេងទៀត។ ក្នុងន័យនេះ អង្គការសហប្រជាជាតិបន្តលើកទឹកចិត្ត និងគាំទ្រឱ្យអាជ្ញាធរអនុវត្តវិធានការទាំងឡាយ ដូចជា ការសង្កេតឃ្លាំមើលឱ្យបានល្អត់ល្អន់ ការធ្វើតេស្តជាយុទ្ធសាស្ត្រ ការកំណត់រកករណីឱ្យបានទាន់ពេលវេលា ការដាក់ឱ្យនៅដោយឡែក និងការថែទាំគ្លីនិក ក៏ដូចជាការពាក់ម៉ាស់ ការធ្វើអនាម័យដៃ និងការរក្សាគម្លាតសុវត្ថិភាពជាដើម។ អង្គការសហប្រជាជាតិបន្តជំរុញឱ្យមានការផ្តល់វ៉ាក់សាំងដល់ក្រុមដែលប្រឈមមុខខ្ពស់ជាងគេសិន និងត្រូវពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីធានាឱ្យមានទិន្នន័យបែងចែកតាមប្រភេទលម្អិតសម្រាប់យកមកធ្វើការវិភាគ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងកំណត់រកក្រុមប្រឈមមុខនឹងហានិភ័យខ្ពស់ និងធានាឱ្យមានការចាក់វ៉ាក់សាំងប្រកបដោយសមធម៌។ អង្គការសហប្រជាជាតិក៏ជំរុញឱ្យមានការបន្តចូលរួមពីសហគមន៍ និងការអប់រំផ្សព្វផ្សាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកាត់បន្ថយការចម្លងជំងឺកូវីដ-១៩ ទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានមិនពិត និងបង្កើនការទទួលយកវ៉ាក់សាំងកូវីដ-១៩។ ការស្តារឡើងវិញអំពីការរាតត្បាតជាសកលប្រកបដោយចីរភាព ទាមទារឱ្យមានការពង្រឹងប្រព័ន្ធថែទាំសុខភាព និងពង្រឹងការត្រៀមបង្ការទប់ទល់នឹងស្ថានភាពអាសន្នផ្នែកសុខភាពដែលអាចកើតមាននាពេលអនាគត។ នៅកម្រិតសកល អង្គការសហប្រជាជាតិបានអំពាវនាវឱ្យមានសាមគ្គីភាពជាសកល ដើម្បីទប់ស្កាត់នឹងវីរុសនេះ និងជំរុញឱ្យប្រជាពលរដ្ឋនៅក្នុងគ្រប់ប្រទេសទាំងអស់បានទទួលវ៉ាក់សាំងប្រកបដោយយុត្តិធម៌ សមធម៌ និងសុវត្ថិភាព។ អង្គការសហប្រជាជាតិនៅកម្ពុជា នៅតែបន្តប្តេជ្ញាជួយដល់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ និងការចាក់វ៉ាក់សាំង ដើម្បីការពារពលរដ្ឋ សង្គ្រោះអាយុជីវិត និងធានាឱ្យការស្តារឡើងវិញពីការរាតត្បាតជាសកលកាន់តែមានភាព ធន់។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបរបស់អង្គការសហប្រជាជាតិនៅកម្ពុជាចំពោះបញ្ហាកូវីដ-១៩ គឺជាឯកសារផ្លូវការដែលចងក្រងដោយអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអ្នកសារព័ត៌មាន និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង កញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង និងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល៖ sreysros.keo@un.org។